**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

# របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ២០១៩
# កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## ១. សេចក្តីផ្តើម

ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាន អនុវត្តផែនការសកម្មភាពលម្អិតតាមគោលដៅនៃសូចនាករសមិទ្ធកម្មគន្លឹះប្រចាំឆ្នាំ២០១៩ ដែលមានសកម្មភាព ចំនួន៣៩ និងសូចនាករចំនួន៤៤ សម្រេចបានដូចខាងក្រោមៈ

## ២. វឌ្ឍនភាពប្រចាំត្រីមាសទី៤

- មានសកម្មភាពចំនួន៣១ និងសូចនាករចំនួន៣៣ សម្រេចបានតាមគោលដៅ ១០០% និងសកម្មភាព មិនបានអនុវត្តមាន០១
- ១១.១.២. រៀបចំរបាយការណ៍ពិនិត្យនិងវាយតម្លៃការអនុវត្តការប្រមូលចំណូលស្របតាមយុទ្ធសាស្ត្រ កៀរគរចំណូលឆ្នាំ២០១៩-២០២៣សកម្មភាព សម្រេចបាន ៩០%
- ១១.១.៣. រៀបចំសេចក្តីព្រាងច្បាប់ស្តីពីការការពារដំណាំនិងភូតគាមអនាម័យ សម្រេចបាន ៩៣%
- ១១.១.៤. រៀបចំអនុក្រឹត្យស្តីពីការបង្កើតអង្គភាព/លេខាធិការដ្ឋានគ្រប់គ្រងពូជដំណាំ សូចនាករទី២ សម្រេចបាន ៥០%
- ១១.៣.១. ពិនិត្យនិងរៀបចំផ្ទេរការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងសេវាធារណៈរបស់រដ្ឋបាល ជលផល (ខ័ណ្ឌរដ្ឋបាលជលផល) ទៅមន្ទីរកសិកម្មរាជធានី ខេត្ត និង ២២.១.១. ពិនិត្យឡើងវិញនីតិវិធី អនុវត្តការងារនិងឈានទៅកាត់បន្ថយដំណើរការប្រតិបត្តិការលំហូរចំណាយបច្ចុប្បន្ន សម្រេចបាន ៥០%
- ៣១.១.១. ពង្រឹងប្រព័ន្ធតាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីតាមប្រព័ន្ធព័ត៌មានវិទ្យា សម្រេច បាន ៩១%
- ៣១.១.២. របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស និងឆ្នាំ ត្រូវបានផ្សព្វផ្សាយ លើគេហទំព័ររបស់ក្រសួង សម្រេចបាន ៨៥%
- ៣២.១.៤ រៀបចំផែនការមេសម្រាប់អភិវឌ្ឍវិស័យកសិកម្ម ២០៣០ សម្រេចបាន ៨០%
- ៤៣.៣.២.អនុសាសន៍/វិធានការដែលបានលើកឡើងដោយអគ្គាធិការដ្ឋាន ត្រូវបានកែលម្អ និងដាក់ ឲ្យអនុវត្ត សម្រេចបាន ៨៧%
- ៤៣.៤.២. ការធ្វើអធិការកិច្ចលើការងារដឹកនាំ និងគ្រប់គ្រង អង្កេតស្រាវជ្រាវពាក្យបណ្តឹង និងតាមដាន ការអនុវត្តច្បាប់

## ៣. បញ្ហាប្រឈមៈ

- មន្ទីរមិនអាចគ្រោងនិងកត់ត្រាចំណូលពីផលនេសាទបានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបន្តគ្រោងផែនការចំណូលនេះនៅរដ្ឋបាលកណ្តាលសម្រាប់ឆ្នាំ២០២០
- អង្គភាពមួយចំនួនមិនទាន់យល់ច្បាស់ក្នុងការបំពេញទម្រង់របាយការណ៍ M&E តាមប្រព័ន្ធ Online
- សមត្ថភាពរបស់មន្ត្រីដែលអនុវត្តសកម្មភាពការងារនៅមានកម្រិត

## ៤. សំណើ និងសំណូមពរៈ

- ស្នើក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រៀបចំប្រកាសស្តីពីផ្ទេរតណាទានចំណូលផលនេសាទនេះជូនមន្ទីររាជធានី ខេត្ត
- តម្រូវការវគ្គបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពមន្ត្រី
- ថវិកាបន្ថែមសម្រាប់អនុវត្តសកម្មភាព

## ៥. សន្និដ្ឋាន

- របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរួមដំណាក់កាលទី៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលបានអនុវត្តក្នុងឆ្នាំ២០១៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រេចបានជាលទ្ធផលគួរឲ្យកត់សម្គាល់ ទោះជាមានសកម្មភាព និងសូចនាករមួយចំនួនមិនអាចសម្រេចបានតាមផែនការក៏ដោយ។
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងខិតខំបន្តកិច្ចសហការជាមួយ អគ្គលេខាធិកាដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីឲ្យអនុវត្តផែនការសកម្មភាពរួមដំណាក់កាលទី៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃឆ្នាំបន្តបន្ទាប់សម្រេចបានលទ្ធផល១០០% ទៅតាមផែនការ និងសូចនាករដែលបានកំណត់ប្រកបដោយស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាព។

ថ្ងៃពុធ ១៣រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមករា ឆ្នាំ២០២០

អ្នករៀបចំរបាយការណ៍

បានឃើញ និងឯកភាព

ថ្ងៃ ច័ន្ទ ៣កើត ខែ មាឃ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០២០

ប្រធានក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ